ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ១៨៧

ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១

សាលដីកា

លេខ: ២៤២

ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម:

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោកស្រី [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្ដឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៥៤ ក្រVIញ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ១៨៧ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១ របស់តុលាការកំពូល។

<u>តីបទ:</u> បរិហារកេរ្តិ៍ និងជេរប្រមាថ ប្រព្រឹត្តនៅភូមិរការគយ(ខ) ឃុំរការគយ ស្រុកកងមាស ខេត្តកំពង់ចាម កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា៦៣ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ព្រហ្មទណ្ឌអន្តរកាល។

១-ជនជាប់ចោទឈ្មោះ [redacted] "ម្ចាស់បណ្ដឹងសាទុក្ខ" ភេទប្រុស អាយុ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅសព្វថ្ងៃភូមិរការគយ(ខ) ឃុំរការគយ ស្រុកកងមាស ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] "រ" មានកូន០២នាក់ ទោសពីមុនគ្មាន។

២-ជនជាប់ចោទឈ្មោះ [redacted] ម្ចាស់បណ្ដឹងសាទុក្ខ" ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើត និងទីលំនៅសព្វថ្ងៃភូមិរការគយ(ខ) ឃុំរការគយ ស្រុកកងមាស

ខេត្តកំពង់ចាម ប្ដីឈ្មោ[redacted]"រ" មានកូន០២នាក់ ឪពុកឈ្មោ[redacted]" ម្ដាយឈ្មោះ [redacted]" ទោសពីមុនគ្មាន។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]ភេទស្រី អាយុ៤៣ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិរការគយ(ខ) ឃុំរការគយ ស្រុកកងមាស ខេត្តកំពង់ចាម មុខរបរធ្វើស្រែ ប្ដីឈ្មោះ[redacted]រ" លែងលះ ឪពុកឈ្មោះ[redacted]" ម្ដាយឈ្មោះ[redacted]រ" ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិរការគយ(ខ) ឃុំរការគយ ស្រុកកងមាស ខេត្តកំពង់ចាម មុខរបរធ្វើស្រែ ប្ដីឈ្មោះ [redacted] "រ" ឪពុកឈ្មោះ[redacted] "រ" ម្ដាយឈ្មោះ[redacted]រ"។

-តាមពាក្យបណ្ដឹងចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ[redacted] ថា: កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ វេលាប្រហែល ៣:០០ រសៀល ឈ្មោ[redacted]បានជេរមកលើកូនរបស់ខ្លួនឈ្មោះ [redacted]ថា ឯែងលួចដករបងដាក់ចូលដីអញ ឯែងយកប្ដីគេបានកូន០៥ខែមីចោរគេចុយ។ បន្ទាប់មកឈ្មោះ[redacted]បានជេរខ្លួនថា មីព្រាត់ប្រាស់ប្ដី មីតែហោង មីដកមមីសដាក់ក្បាលគេ ឯែងចង់ដកដាក់អ្នកផ្សារដាក់ទៅ និងជេរខ្លួនជាច្រើនទៀត។

-បានឃើញសេចក្ដីសន្និដ្ឋានតំណាងរយ្យការសាលាដំបូងខេត្តកំពង់ចាមថា: ចោទប្រកាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិរការគយ(ខ) ឃុំរការគយ ស្រុកកងមាស ខេត្តកំពង់ចាម។ ពីបទ: បរិហាកេរ្តិ៍ និងជេរប្រមាថប្រព្រឹត្តនៅភូមិរការគយ(ខ) ឃុំរការគយ ស្រុកកងមាស ខេត្តកំពង់ចាម កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា៦៣ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មមាត្រា៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៣៧៨ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពង់ចាម ដែលបានសម្រេច:

១-ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ៖

ក-[redacted]ភេទប្រុស អាយុ៤៣ឆ្នាំ ជាតិខ្មែរ (សារធាតុដូចខាងលើ)

ខ-[redacted]ភេទស្រី អាយុ៣៨ឆ្នាំ ជាតិខ្មែរ (សារធាតុដូចខាងលើ)

ពិន័យជាប្រាក់ក្នុងមួយនាក់ចំនួន ១.០០០.០០០ (មួយលានរៀល) ពីបទ ជេរប្រមាថ និងបរិហាកេរ្តិ៍ ប្រព្រឹត្តនៅភូមិរការគយ(ខ) ឃុំរការគយ ស្រុកកងមាស ខេត្តកំពង់ចាម កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា៦៣ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោ[redacted]និងឈ្មោ[redacted]រួមគ្នាសងសំណងជំងឺចិត្តទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted]ចំនួន២.៥០០.០០០ (ពីរលានប្រាំសែនរៀល)។

ការទាមទារលើសពីនេះបដិសេធចោល។



Scanned by CamScanner

៣-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទ

ឈ្មោះ [redacted] ឈ្មោះ [redacted] និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] និងឈ្មោះ [redacted]

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៥០ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] និងឈ្មោះ [redacted] ប្តឹងមិនសុខចិត្តនឹងសាលាក្រមព្រហ្មទណ្ឌលេខ៣៧៨ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពង់ចាម ត្រង់ចំណុចទី១ និងចំណុចទី២ នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា: ចំពោះសភាព្រហ្មទណ្ឌសម្រេច:

-ទទួលបណ្តឹងឧទ្ធរណ៍លេខ៥០ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៩២(ង) ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពង់ចាម ទុកជាបានការដដែល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៥៤ ក្រVIញ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច:

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] និងឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៩២ (ង) ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពង់ចាម ទុកជាបានការពេញទាំងមូល។

៣-សាលដីកាប្រកាសជាសាធារណៈនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខលេខ១៩៤ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] និងឈ្មោះ [redacted] មិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៥៤ ក្រVIញ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណាការពាររបស់ឈ្មោះ [redacted] ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១១ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់។

-បានឃើញសារណាតបរបស់ឈ្មោះ [redacted] ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់។



Scanned by CamScanner

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា:

១-ទទួលបណ្តឹងសាទុក្ខលេខ១៩៤ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] និងឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយខុសទៅនឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៥៤ ក្រVIញ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេចតាមច្បាប់។

-បានស្តាប់សាវតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្ម[redacted]ពេលសវនាការថា: តើអ្នកឯងប្តឹងសាទុក្ខដោយមូលហេតុអ្វី? ពីដំបូងកូនគោរបស់ខ្លួនចូលទៅផ្ទះឈ្មោះ [redacted] តាមរបងដោយមានការខូចខាតរបង ខ្លួនក៏ទៅជួសជុលសងវិញ ពេលនោះឈ្មោះ [redacted] ក៏មកដករបងដែលខ្លួនជួសជុលនោះចោលវិញ ហើយក៏ជេរខ្លួនថា អាតែហោង និងបានបបួលខ្លួនវាយគ្នា ខ្លួនក៏ថាស្រីស៊ីជួអាងអីហៅខ្លួនមកវាយគ្នា។ ខ្លួនមិនបានជេរអ្វីប៉ះពាល់ដល់ដើមបណ្តឹងទេ។

-បានស្តាប់សាវតាជាតិ និងចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] និ[redacted]នាពេលសវនាការថា: មុនដំបូងខ្លួនគ្រាន់តែជេរថា មីតែហោង អាមេម៉ាយ មីការប្តីបាន៦ខែកើតកូន ហើយក៏បានជេរទៀតថា អាផ្អែមវិញទៅ។ ឈ្មោះ [redacted] ថា ខ្លួនបានការពេញច្បាប់ ហើយឈ្មោះ [redacted] ថា ខ្លួនយកប្តីគេការបាន៦ខែកើតកូន។ ដូច្នេះ សុំឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងអយ្យការអមតុលាការកំពូលថា: ពុំមានយោបល់អ្វីបន្ថែមទៀតទេ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

<u>តុលាការកំពូល</u>

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៩៤ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] និងឈ្មោះ [redacted] ស្ថិតនៅក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា១៩ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned by CamScanner

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ៩២"ង" ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តកំពង់ចាម ទុកជាបានពេញទាំងមូលនោះជាការមិនត្រឹមត្រូវទេ ពីព្រោះមាត្រា៦៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៦៣ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ត្រូវបាននិរាករណ៍តាមមាត្រា៦៧១ នៃក្រមព្រហ្មទណ្ឌហើយ។

-យល់ឃើញថា ប្រាក់ជំងឺចិត្តដែលត្រូវបានតុលាការអង្គសេចក្តីសម្រេចមានលក្ខណៈធ្ងន់ធ្ងរ មិនសមស្របនឹងចំណូលរបស់អ្នកទាំងពីរជាកសិករទេ ហើយការប៉ាន់ប្រមាណការខូចខាតខាងផ្លូវចិត្តក៏មិនមានលក្ខណៈសមស្របដែរ។ ដូច្នេះគប្បីសាលាឧទ្ធរណ៍ពិចារណាជាថ្មី។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៥៤ ក្រVI"ញ" ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ ខុសនឹងគតិច្បាប់។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ១៩៤ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ របស់ឈ្មោះ[redacted] និងឈ្មោះ[redacted]។

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ៥៤ ក្រVIញ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ១៨៧ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះឡើងវិញ។

៤-សាលដីកានេះជំនុំជំរះនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៣។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣

ជ. ប្រធានតុលាការកំពូល

អនុប្រធាន

[redacted]